**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៦១)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៨ ៦៩៣នាក់ នៃរោងចក្រ សហគ្រាសទាំង៤៩ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីងនឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ៧៥០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីងនឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង៤៩ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ១០កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០២១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៤៩ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 13 |
| 1 | ក្រុមហ៊ុន យ៉ាកជីន (ខេមបូឌា) អ៊ីន | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ធីមប៊ីរមេធ (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ផ្លេកថាម (ខេមបូឌា) អឹភែរឹល លីមីធីត | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហ្សាក់ស៊ីនតិច អ៊ីនដាស់ស្រ្ទីស៍ ខេមបូឌា ខូ អិលធីឌី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ត្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 6 | ក្រុមហ៊ុន ហ្សុងហ្គ័រយុនជីន (ខេមបូឌា) ហ្គាមេន ខូអិលធីឌី | កំពង់ស្ពឺ |
| 7 | ក្រុមហ៊ុន ដេស៊ឹង ខេមបូ ខូអិលធីឌី | កំពង់ស្ពឺ |
| 8 | ក្រុមហ៊ុន ស៊ីអិនឌីហ្វ្រី អិនធើណេសិនណល (ខេអេច) ឯ.ក | កំពង់ស្ពឺ |
| 9 | ក្រុមហ៊ុន ដាតាន់ អ៊ិនដាសស្ទ្រៀល ឯ ក ស្រុកព្រៃឈរ ខេត្តកំពង់ចាម | កំពង់ចាម |
| 10 | ក្រុមហ៊ុន ស៊ូភើ លីង ហ្វេសិន (ខេមបូឌា)ឯ.ក | កំពង់ឆ្នាំង |
| 11 | ក្រុមហ៊ុន ស្រ្តង ហៃលធ៍ អ៊ិនធើណេសិនណល លីមីធីត | តាកែវ |
| 12 | ក្រុមហ៊ុន ខតចិនខនសិប អ៊ិនដាសស្ទ្រី ឯ.ក | តាកែវ |
| 13 | ក្រុមហ៊ុន ញូវ ស្តារ ស៊ូ ខូអិលធីឌី | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | ៣៦ |
| 14 | ក្រុមហ៊ុន អិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 15 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 16 | ក្រុមហ៊ុន អេច ជី ប៊ី ហ្វូដ អ៊ិនដាសស្ទ្រី (ច្បារអំពៅ) | ភ្នំពេញ |

| ល.រ | ឈ្មោះគោលដៅចរ្យា សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន អេច ជី ប៊ី ហ្វូដ អ៊ិនជាសស្ទ្រី (ជូនពេញ) | ភ្នំពេញ |
| 18 | ក្រុមហ៊ុន ភីអេស សហការ ឯ.ក | ភ្នំពេញ |
| 19 | ក្រុមហ៊ុន ឌីថាមត្រាវែល ខេមបូឌា | ភ្នំពេញ |
| 20 | ក្រុមហ៊ុន ញូ យ៉ក ហូថេល & សឺវិស អឹផាតមិន | ភ្នំពេញ |
| 21 | ក្រុមហ៊ុន រ៉េមប៊ូធិន រីសត ខេមបូឌាន | ភ្នំពេញ |
| 22 | ក្រុមហ៊ុន អេឃ្សើ អេកស្ពឺឌីសិន (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 23 | ក្រុមហ៊ុន សិប្បករអង្គរ ភ្នំពេញ | ភ្នំពេញ |
| 24 | ក្រុមហ៊ុន ថាលាស | ភ្នំពេញ |
| 25 | ក្រុមហ៊ុន ស្ពាយឃើង ត្រាវែល & ធួរ | ភ្នំពេញ |
| 26 | ក្រុមហ៊ុន អលឌ្រីម (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 27 | ក្រុមហ៊ុន បាហ្វឺឡូធួរ (ខេមបូឌា) លីមីតធីត | សៀមរាប |
| 28 | ក្រុមហ៊ុន ម៉ុនស៊ូន អេស៊ាន ប៊ីស្ត្រូ | សៀមរាប |
| 29 | សណ្ឋាគារ អូរៀនថល ដេ7 | សៀមរាប |
| 30 | ក្រុមហ៊ុន អាហារដ្ឋានផ្ទះបាយខ្មែរភឿក | សៀមរាប |
| 31 | ក្រុមហ៊ុន កូបេ យ៉ៃភែននីស រ៉េស្តូរ៉ែន | សៀមរាប |
| 32 | សណ្ឋាគារ សុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 33 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 34 | សណ្ឋាគារ សាឯមសៀមរាប | សៀមរាប |
| 35 | ក្រុមហ៊ុន កាឡាស ខម(ខេមបូឌា)ភីធីអ៊ី អិលធីឌី (សណ្ឋាគារ អង្គរ អេរ៉ា) | សៀមរាប |
| 36 | ក្រុមហ៊ុន ហ្វូខឹស អេស៊ា អ៊ីនធើណេសិនណលត្រាវែល សឺវីស | សៀមរាប |
| 37 | សណ្ឋាគារ អង្គរហូតែលគ្រុប (សណ្ឋាគារ អប្សរា ផាឡេស) | សៀមរាប |
| 38 | សណ្ឋាគារគោព្រៃ | សៀមរាប |
| 39 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 40 | ក្រុមហ៊ុន មុទិតា រីសត & ស្ប៉ា | សៀមរាប |
| 41 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 42 | ក្រុមហ៊ុន អង្គរ ហូលីដេ | សៀមរាប |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 43 | ក្រុមហ៊ុន រេសថឺរេន ខូឡិចហ្សិន | សៀមរាប |
| 44 | ក្រុមហ៊ុន ហាប់ ហេង អ៊ិនវេសមេន ភីធីអ៊ី អិលធីឌី | សៀមរាប |
| 45 | ក្រុមហ៊ុន GB II Co., LTD | សៀមរាប |
| 46 | ក្រុមហ៊ុន ហ្គោថូន ត្រាវែល សឺវីស | សៀមរាប |
| 47 | ក្រុមហ៊ុន បា ឡឺ កូដ ត្រេឌីង | សៀមរាប |
| 48 | ផ្ទះសំណាក់ សាគូអង្គ | សៀមរាប |
| 49 | ក្រុមហ៊ុន អ៊ិនឌីភែនដឹនថ៍ ហូថេល | ព្រះសីហនុ |